**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**កំពង់ផែស្វយ័តភ្នំពេញ**

លេខ ០៦៨/១៩ ក. ស. ភ.

ថ្ងៃចន្ទ ១៣កើត ខែ ផល្គុន ឆ្នាំច សំរឹទ្ធិស័ក ព. ស. ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១៩

# សេចក្តីជូនដំណឹង

## ស្តីពី

## មហាសន្និបាតភាគហ៊ុនិកលើកទី៤ របស់កំពង់ផែស្វយ័តភ្នំពេញ

**កំពង់ផែស្វយ័តភ្នំពេញ** (**ក. ស. ភ.**) មានកិត្តិយសសូមជម្រាបជូនដំណឹងដល់ភាគហ៊ុនិកកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតប្រភេទ "**ក**" និងប្រភេទ "**ខ**" របស់ **ក. ស. ភ.** ទាំងអស់មេត្តាជ្រាបថា យោងតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ក. ស. ភ. ក្នុងកិច្ចប្រជុំលើកទី១៨ អាណត្តិទី៦ នាថ្ងៃទី៥ ខែមីនា ឆ្នាំ២០១៩ **ក. ស. ភ.** នឹងរៀបចំមហាសន្និបាតភាគហ៊ុនិកលើកទី៤ តាមការកំណត់ដូចខាងក្រោម៖

១. កាលបរិច្ឆេទកំណត់ទុក (Record Date) ÷ **ថ្ងៃទី៣ ខែមេសា ឆ្នាំ២០១៩**

២. កាលបរិច្ឆេទប្រារព្ធមហាសន្និបាតភាគហ៊ុនិកលើកទី៤ ÷ **ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៩**

៣. ទីកន្លែងនៃមហាសន្និបាតភាគហ៊ុនិកលើកទី៤ ÷ សាលប្រជុំជាន់ទី៣ នៃអគាររដ្ឋបាល ទីស្នាក់ការកណ្តាល ក. ស. ភ. (ចំណតផែថ្មី TS៣) ដែលស្ថិតនៅអគារលេខ ៦៤៩ វិថីព្រះស៊ីសុវត្ថិ សង្កាត់-ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ។

៤. របៀបវារៈនៃមហាសន្និបាតភាគហ៊ុនិកលើកទី៤ រួមមាន ÷

   ក. របាយការណ៍ស្តីពីលទ្ធផលការងារប្រចាំឆ្នាំ២០១៨

   ខ. ការលើកទិសដៅការងារអនុវត្តបន្តឆ្នាំ២០១៩

   គ. ការបោះឆ្នោតជ្រើសរើសអភិបាលឯករាជ្យ និងអភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជន សម្រាប់អាណត្តិទី៧ នៃក្រុមប្រឹក្សាភិបាល ក. ស. ភ.

ភាគហ៊ុនិកដែលមានឈ្មោះក្នុងបញ្ជីឈ្មោះភាគហ៊ុនិក នាថ្ងៃទី៣ ខែមេសា ឆ្នាំ២០១៩ (កាលបរិច្ឆេទកំណត់ទុក) នឹងទទួលបានលិខិតអញ្ជើញ តាមរយៈសារអេឡិចត្រូនិកពី **ធនាគារ អេស៊ីលីដា ភីអិលស៊ី** (ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ និងភ្នាក់ងារទូទាត់របស់ ក. ស. ភ.) ឬ អាចអញ្ជើញមកទទួលលិខិតអញ្ជើញនៅទីស្នាក់ការកណ្តាលរបស់ **ក. ស. ភ.** ដែលមានអាសយដ្ឋាននៅ អគារលេខ ៦៤៩ វិថីព្រះស៊ីសុវត្ថិ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ នៅរៀងរាល់ម៉ោងធ្វើការ ចាប់ពី **ថ្ងៃទី៩ ខែមេសា ឆ្នាំ២០១៩ ដល់ថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១៩**។



ទីស្នាក់ការកណ្តាល៖ អគារលេខ ៦៤៩ គីវវិថីព្រះស៊ីសុវត្ថិ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ/ទូរសារ (៨៥៥) ២៣ ៩២៧ ៨០២ Email: ppapmpwt@online.com.kh / info@ppap.com.kh

បន្ទាប់ពីទទួលបានលិខិតអញ្ជើញតាមរយៈសេចក្តីជូនដំណឹងខាងលើ សូមភាគហ៊ុនិកទាំងអស់មេត្តាបញ្ជាក់អំពីការចូលរួមទៅ **ធនាគារ អេស៊ីលីដា ភីអិលស៊ី** តាមរយៈសារអេឡិចត្រូនិច និងលេខទំនាក់ទំនងដូចបញ្ជាក់ជូនខាងក្រោម **ចាប់ពីថ្ងៃទី៩ ខែមេសា ឆ្នាំ២០១៩ ដល់ថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១៩**។

- បញ្ជាក់ ÷ ភាគហ៊ុនិកដែលអញ្ជើញមកចូលរួមមហាសន្និបាតភាគហ៊ុនិក សូមភ្ជាប់មកជាមួយនូវលិខិតអញ្ជើញដែលបានប្រគល់ជូន/ផ្ញើជូន ដើម្បីចុះវត្តមានក្នុងមហាសន្និបាតភាគហ៊ុនិកលើកទី៤ របស់ ក. ស. ភ.។

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងមក **ធនាគារ អេស៊ីលីដា ភីអិលស៊ី** និងកំពង់ផែស្វយ័តភ្នំពេញ តាមអាសយដ្ឋាន និងលេខទំនាក់ទំនង ដូចខាងក្រោម÷

**១.ធនាគារ អេស៊ីលីដា ភីអិលស៊ី**

- អាសយដ្ឋាន÷ជាន់ទី៥អគារលេខ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ
- ទូរសព្ទ ÷ (៨៥៥) ២៣ ៩៩៨ ៧៧៧ (Ext : ០៥០១៣)
- ទូរសារ ÷ (៨៥៥) ២៣ ៩៩៨ ៦៦៦
- ទូរសព្ទដៃ ÷ (៨៥៥) ១៥ ៦០០ ៧៤៣ (Ext : ០៥០១៣)<br>(៨៥៥) ១៥ ៩០០ ៥៣៨ (Ext : ០៥០២០)<br>(៨៥៥) ៦១ ២៨៧ ៧៦៦ (Ext :០៥០២០)
- សារអេឡិចត្រូនិក ÷ lim.an@acledabank.com.kh/lim.pengan@gmail.com

**២.កំពង់ផែស្វយ័តភ្នំពេញ**

- អាសយដ្ឋានអគារលេខ ៦៤៩ វិថីព្រះស៊ីសុវត្ថិ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ
- ទូរសព្ទដៃ÷ ០១០ ៨៤៤ ៣៦៧/០១០ ៨៤៤ ៣៧៥ /០១០ ៨៤៤ ០១៧
- អ៊ីម៉ែល ÷ ppapmpwt@online.com.kh

**ជ. គណៈកម្មការរៀបចំមហាសន្និបាតភាគហ៊ុនិកលើកទី ៤**

**ប្រធាន**

ហ៊ី-ប្ញាវី

ចម្លងជូន÷
-ក្រសួងសាធារណការ និងដឹកជញ្ជូន
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-គណៈកម្មការមូលបត្រកម្ពុជា (គ. ម. ក)
-សមាជិកក្រុមប្រឹក្សាភិបាល ក. ស. ភ.
-សវនករផ្ទៃក្នុងរបស់ ក. ស. ភ.
-សវនករឯករាជ្យរបស់ ក. ស. ភ. - ក្រុមហ៊ុន BDO
*"ដើម្បីជូនជ្រាប"*
-ធនាគារ អេស៊ីលីដា ភីអិលស៊ី
(ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ និងភ្នាក់ងារទូទាត់)
*"ដើម្បីសហការផ្សព្វផ្សាយ"*
-ឯកសារ-កាលប្បវត្តិ

**KINGDOM OF CAMBODIA**

**Nation Religion King**

**Phnom Penh Autonomous Port**

Nº: ....069/....19.....PPAP

PHNOM PENH, Date: March 18, 2019

# Announcement

# On

# The 4th General Shareholders Meeting of Phnom Penh Autonomous Port

**Phnom Penh Autonomous Port (PPAP)** is honored to announce to all PPAP's shareholders that according to PPAP's Board of Directors resolution in the 14th meeting of the 6th mandate on March 4th, 2019, PPAP will hold the 4th General Shareholders Meeting as follows:

**1.** Record Date: **April 3rd, 2019**

**2.** Date of the 4th General Shareholders Meeting: **April 23rd, 2019**

**3.** Venue: 3rd floor meeting hall of PPAP's Head Office (TS3) located at #649, Preah Sisowath Street, Sangkat Sras Chork, Khan Daun Penh, Phnom Penh.

**4.** Agenda:

- **a.** Report on Business Performance of 2018
- **b.** Future Plan for 2019
- **c.** The Election of Independent Director and Non-Executive Director as a Representative of Private Shareholders for the 7th Mandate of PPAP's Board of Directors.

Shareholder, whose name is in shareholders list on April 3rd, 2019 (Record Date), will receive the invitation letter through the email from ACLEDA Bank Plc. (securities transfer agent and settlement agent of PPAP) or can be collected from PPAP's Head Office located at #649, Preah Sisowath Street, Sangkat Sras Chork, Khan Daun Penh, Phnom Penh during working hours from April 9th to April 19th, 2019.

After receiving the invitation letter, please kindly confirm your participation to **ACLEDA Bank Plc.** via email or contact number as mentioned below from April 9th to April 19th, 2019.



Head Office: # 649, Preah Sisowath Quay, Sangkat Sras Chork, Khan Daun Penh, Phnom Penh Fax/Phone: (855) 23 427 802, Email: ppapmpwt@online.com.kh / info@ppap.com.kh

❖ **Note:** Please kindly bring the invitation letter for registration during PPAP's 4th General Shareholders Meeting.

For more information, please contact to ACLEDA Bank Plc. and PPAP via addresses and contacts as follows:

**1. ACLEDA Bank Plc.**

- Address: 5th floor, #61, Monivong Blvd., Sangkat Sras Chork, Khan Daun Penh, Phnom Penh
- Tel: (855) 23 998 777 (Ext: 05013)
- Fax: (855) 23 998 666
- Hand Phone: (855) 15 600 743 (Ext: 05013)
  (855) 15 900 538 (Ext: 05020)
  (855) 61 287 766 (Ext: 05020)
- Email : lim.an@acledabank.com.kh/lim.pengan@gmail.com

**2. Phnom Penh Autonomous Port**

- Address: #649, Preah Sisowat Street, Sangkat Sras Chork, Khan Daun Penh, Phonm Penh
- Hand Phone: 010 444 367/010 444 375/010 444 017
- Email: ppapmpwt@online.com.kh

**For, Organizing Committee**
**for the 4th General Shareholders Meeting**
**Chairman**

HEI BAVY

**CC÷**

- Ministry of Public Works and Transport
- Ministry of Economy and Finance
- Securities and Exchange Commission of Cambodia
- Cambodia Securities Exchange (CSX)
- PPAP's Board of Directors
- PPAP's Internal Auditor
- PPAP's External Auditor (BDO)
  ***"For Information"***
- Acleda Bank Plc. (securities transfer agent and settlement agent of PPAP)
  ***"For announcement"***
- Documentation